# ផ្នែកទី II

# គំនូសសញ្ញាតាមបណ្តោយទ្រូងផ្លូវ

## ( Longitudinal Markings )

គំនូសសញ្ញា តាមបណ្តោយទ្រូងផ្លូវ ជាខ្សែគំនូសជាប់ ឬ ដាច់ៗ ទោល ឬ ភ្លោះ ពណ៌លឿង ស ឬ ក្រហម ទៅតាមប្រភេទ គំនូសសញ្ញានិមួយៗ ។ ការបើកបរជាន់ពីលើ តាមបណ្តោយគំនូសសញ្ញាប្រភេទនេះ ត្រូវហាមឃាត់ ។

# ផ្នែកទី II : គំនូសសញ្ញាតាមបណ្តោយទ្រូងផ្លូវ ( Longitudinal Markings )



### គំនូសសញ្ញាទោលដាច់ៗ បែងចែកទិសចរាចរ

SINGLE YELLOW BROKEN LINE

**លេខកូដ :PW03-M2-01**

**ខ្លឹមសារ :** គំនូសសញ្ញាទោលដាច់ៗ ពណ៌លឿង តាមបណ្តោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរ ទិសចរាចរផ្ទុយគ្នា អ្នកបើកបរអាចឆ្លងកាត់ ឬ ជែងបាន ។

---



### គំនូសសញ្ញាទោលជាប់ បែងចែកទិសចរាចរ

SINGLE YELLOW SOLID LINE

**លេខកូដ :PW03-M2-02**

**ខ្លឹមសារ :** គំនូសសញ្ញាទោលជាប់ ពណ៌លឿង តាមបណ្តោយ ទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរ ទិសចរាចរផ្ទុយគ្នា និង ហាមបើកបរជាន់ ឬឆ្លងកាត់ ។ គំនូសសញ្ញានេះ ប្រើលើផ្លូវដែលមានចរាចរធម្មតា ។

---



### គំនូសសញ្ញាភ្លោះជាប់ បែងចែកទិសចរាចរ

DOUBLE YELLOW SOLID LINE

**លេខកូដ :PW03-M2-03**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះជាប់ ពណ៌លឿង តាមបណ្តោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរ ទិសចរាចរផ្ទុយគ្នា និង ហាមបើកបរជាន់ ឬឆ្លងកាត់ ។ គំនូសសញ្ញានេះ ប្រើលើផ្លូវដែលមានចរាចរច្រើន ឬនៅត្រង់ផ្លូវកោងគ្រោះថ្នាក់ ឬត្រង់ស្ពាន។

---



### គំនូសសញ្ញាភ្លោះ បែងចែកទិសចរាចរ
### (មានគំនូសដាច់ៗនៅខាងឆ្វេង)

DOUBLE YELLOW COMBINATION LINE

**លេខកូដ :PW03-M2-04**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះ ពណ៌លឿង ដែលមានគំនូសដាច់ៗ នៅខាងឆ្វេង និង គំនូសជាប់នៅខាងស្តាំ តាមបណ្តោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរទិសចរាចរផ្ទុយគ្នា ។ អ្នកបើកបរ នៅកៀកគំនូសដាច់ៗ អាចឆ្លងកាត់ ឬ ជែងបាន ប៉ុន្តែអ្នកបើកបរនៅកៀកគំនូសជាប់ មិនអាចឆ្លងកាត់ ឬ ជាន់បានឡើយ ។



**គំនូសសញ្ញាភ្លោះ បែងចែកទិសចរាចរ**
**(មានគំនូសដាច់ៗនៅខាងស្ដាំ)**
DOUBLE YELLOW COMBINATION LINE

**លេខកូដ :PW03-M2-05**

**ខ្លឹមសារ** : គំនូសសញ្ញាភ្លោះ ពណ៌លឿង ដែលមានគំនូសដាច់ៗ នៅខាងស្ដាំ និង គំនូសជាប់នៅខាងឆ្វេង តាមបណ្ដោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកទ្រូងផ្លូវ ជាពីរទិសចរាចរផ្ទុយគ្នា ។ អ្នកបើកបរ នៅក្បែរគំនូសដាច់ៗ អាចឆ្លងកាត់ ឬ ជែងបាន ប៉ុន្តែអ្នកបើកបរនៅក្បែរ គំនូសជាប់ មិនអាចឆ្លងកាត់ ឬ ជាន់ បានឡើយ ។

---



**គំនូសសញ្ញាដាច់ៗ បែងចែកគន្លងផ្លូវ**
SINGLE WHITE BROKEN LINE

**លេខកូដ :PW03-M2-06**

**ខ្លឹមសារ** : គំនូសសញ្ញាដាច់ៗ ទោលពណ៌ស តាមបណ្ដោយ ទ្រូងផ្លូវ ប្រើសំរាប់បែងចែកគន្លងផ្លូវចរាចរ ។ អ្នកបើកបរ អាចឆ្លងកាត់ ប្ដូរគន្លងផ្លូវបាន ។

---



**គំនូសសញ្ញាជាប់ បែងចែកគន្លងផ្លូវ**
WHITE SINGLE SOLID LINE

**លេខកូដ :PW03-M2-07**

**ខ្លឹមសារ** : គំនូសសញ្ញាជាប់ទោល ពណ៌ស តាមបណ្ដោយទ្រូងផ្លូវ ប្រើសំរាប់បែងចែកគន្លងផ្លូវចរាចរ នៅជិតផ្លូវប្រសព្វ ។ អ្នកបើកបរមិនត្រូវ ឆ្លងកាត់គំនូសនេះ ដើម្បីប្ដូរគន្លងផ្លូវឡើយ ។

---



**គំនូសសញ្ញា កំណត់ជាយផ្លូវ**
EDGE LINE

**លេខកូដ :PW03-M2-08**

**ខ្លឹមសារ** : គំនូសសញ្ញាជាប់ទោលពណ៌ស តាមបណ្ដោយជាយផ្លូវ ប្រើសំរាប់កំណត់ជាយផ្លូវអោយយានជំនិះធ្វើចរាចរ ។



**គំនូសសញ្ញាទោល លឿង_ស លើគែមចិញ្ចើមផ្លូវ**

YELLOW-WHITE CURB MARKINGS

**លេខកូដ :PW03-M2-09**

**ខ្លឹមសារ :** គំនូសសញ្ញា ទោលពណ៌លឿង_ស តាមបណ្ដោយគែមចិញ្ចើមផ្លូវ ប្រើសំរាប់ ការហាមចត ។

---



**គំនូសសញ្ញាទោល ក្រហម_ស លើគែមចិញ្ចើមផ្លូវ**

RED-WHITE CURB MARKINGS

**លេខកូដ :PW03-M2-10**

**ខ្លឹមសារ :** គំនូសសញ្ញា ទោលពណ៌ក្រហម_ស តាមបណ្ដោយគែមចិញ្ចើមផ្លូវ ប្រើសំរាប់ ការហាមឈប់ ។

---



**គំនូសសញ្ញាខ្មៅលឿង លើខឿនទ្រូងផ្លូវ**

BLACK-YELLOW ROAD ISLAND

**លេខកូដ :PW03-M2-11**

**ខ្លឹមសារ :** គំនូសសញ្ញាខ្មៅលឿង លើខឿនទ្រូងផ្លូវ ប្រើសំរាប់ អោយអ្នកបើកបរប្រុងប្រយ័ត្ន មានខឿនលើទ្រូងផ្លូវ ។